# កិច្ចព្រមព្រៀងក្របខ័ណ្ឌសកល

រវាង

**TCHIBO GmbH**

ចុះបញ្ជីនៅ Überseering 18, 22297 Hamburg, ប្រទេសអាល្លឺម៉ង់

- ចាប់ពីពេលនេះតទៅហៅថា "**Tchibo**" –

និង

**INDUSTRIALL GLOBAL UNION**

ចុះបញ្ជីនៅ 54bis, Route des Acacias 1227 Carouge, Geneva, ប្រទេសស្វីស

- ចាប់ពីពេលនេះតទៅហៅថា "**IndustriALL Global Union**" –

# ស្តីពីការអនុវត្តបទដ្ឋានការងារអន្តរជាតិ ដោយក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល មិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo

## បុព្វកថា

1. ក្រុមហ៊ុន Tchibo GmbH ជាក្រុមហ៊ុនលក់រាយលក្ខណៈគ្រួសារនៃប្រទេសអាល្លឺម៉ង់ ដែលភាគច្រើនលក់កាហ្វេ និងផលិតផលសម្រាប់អ្នកប្រើប្រាស់។ ប្រភេទផលិតផលមិនមែនម្ហូបអាហាររួមមាន សម្លៀកបំពាក់ វាយនភ័ណ្ឌប្រើនៅផ្ទះ សម្ភារៈផ្ទះបាយ គ្រឿងសង្ហារឹម គ្រឿងអលង្ការ អេឡិចត្រូនិក សម្ភារៈតុបតែងខ្លួន និងវត្ថុឬសម្ភារៈប្រើក្នុងផ្ទះជាដើម។ ជាមួយនឹងយុទ្ធសាស្រ្តក្រុមហ៊ុនរបស់ខ្លួន ក្រុមហ៊ុន Tchibo ប្តេជ្ញាចិត្តលើកកម្ពស់ និងការពារសិទ្ធិមនុស្សនិងបរិស្ថាន។
2. សហជីព IndustriALL Global Union មានសហជីព និងសហព័ន្ធសហជីព ដែលរៀបចំចងក្រងកម្មករនៅក្នុងវិស័យឧស្សាហកម្មទាំងមូល ដែលរួមមានវិស័យកាត់ដេរ វាយនភ័ណ្ឌ ស្បែកជើង សម្លៀកបំពាក់ស្បែកសត្វ និងឧស្សាហកម្មផុនស្រាលផ្សេងទៀត។ សហជីព ប្តេជ្ញាចិត្តការពារសិទ្ធិ និងផលប្រយោជន៍កម្មករនៅកម្រិតសកល តំបន់ និងអនុតំបន់ តាមរយៈការលើកកម្ពស់បទដ្ឋានការងារអន្តរជាតិនៅក្នុងបណ្តាញផ្គត់ផ្គង់ជាសកល។
3. តាមរយៈកិច្ចព្រមព្រៀងក្របខ័ណ្ឌសកល (តាមន័យនេះហៅថា "កិច្ចព្រមព្រៀង"), ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union (តាមន័យនេះហៅថា "ភាគី") មានបំណងបង្កើតជាផ្លូវការនូវកិច្ចសហប្រតិបត្តិការល្អ ដែលបានអភិវឌ្ឍឡើងនាពេលថ្មីៗនេះ និងចាប់ផ្តើមជាផ្លូវការនូវភាពជាដគូយុទ្ធសាស្រ្ត។
4. កិច្ចព្រមព្រៀងនេះមានគោលបំណងធានាការអនុវត្តបទដ្ឋានការងារអន្តរជាតិទាំងអស់ប្រកបដោយប្រសិទ្ធភាព (រៀបរាប់លម្អិតនៅផ្នែក 6) នៅទូទាំងបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo (កំណត់នៅផ្នែក 10) ដោយផ្តោតសំខាន់លើការពង្រឹងសិទ្ធិសហជីពនិងការចរចារួម។
5. ភាគី យល់ដឹងថា ការអនុវត្តបទដ្ឋានការងារអន្តរជាតិ អាចសម្រេចបានតាមមូលដ្ឋានអចិន្ត្រៃយ៍ និងតាមលក្ខណៈប្រកបដោយចីរភាពតែប៉ុណ្ណោះ ប្រសិនបើ (i) និយោជិតមានសិទ្ធិរៀបចំចងក្រងខ្លួនឯងជាក្រុម និងមានសិទ្ធិក្នុងការចរចារួម ហើយប្រសិនបើ (ii) កម្មករនិយោជិតមានយន្តការនិងមធ្យោបាយត្រួតពិនិត្យ និងដាក់ឱ្យអនុវត្តបទដ្ឋានការងារអន្តរជាតិនៅកន្លែងធ្វើការរបស់ពួកគេ។ ភាគី ជឿជាក់ថាទំនាក់ទំនងវិជ្ជាជីវៈដែលចាស់ទុំ នឹងផ្តល់ប្រយោជន៍ដល់អាជីវកម្មទាំងកម្រិតឧស្សាហកម្មក៏ដូចជានៅកម្រិតរោងចក្រផងដែរ។

## ឯកសារយោងអនុសញ្ញា និងបទដ្ឋាន

6. ទាំងក្រុមហ៊ុន Tchibo និង សហជីព IndustriALL Global Union ត្រូវទទួលស្គាល់ និងធ្វើការសហការគ្នា ដើម្បីធានាការអនុវត្តបទដ្ឋានការងារអន្តរជាតិ (តាមន័យនេះហៅថាអង្គការ "ILO") ដែលរួមមានសេចក្តីប្រកាសអង្គការ ILO ស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ 1998 អនុសញ្ញានិងអនុសាសន៍អង្គការ ILO ដូចខាងក្រោម៖

   C.087 អនុសញ្ញាស្តីពីសេរីភាពសមាគមនិងការការពារសិទ្ធិរៀបចំចងក្រងកម្មករនិយោជិត

   C.087 អនុសញ្ញាស្តីពីសិទ្ធិរៀបចំចងក្រងកម្មករនិយោជិតនិងការចរចារួម

   C.135 អនុសញ្ញាស្តីពីអ្នកតំណាងកម្មករនិយោជិត

   R.143 អនុសាសន៍ស្តីពីអ្នកតំណាងកម្មករនិយោជិត

C.100 អនុសញ្ញាស្ដីពីសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើគ្នា
C.111 អនុសញ្ញាស្ដីពីការរើសអើង (ការងារ និងមុខរបរ)
C.159 អនុសញ្ញាស្ដីពីការស្ដារនីតិសម្បទាផ្នែកវិជ្ជាជីវៈ និងការងារ (ជនពិការ)
C.079 អនុសញ្ញាស្ដីពីការងារពេលយប់សម្រាប់កម្មករនិយោជិតក្មេង (មុខរបរមិនមែនវិជ្ជាជីវៈ)
C.138 អនុសញ្ញាស្ដីពីអាយុអប្បបរមា, C.142 អនុសញ្ញាស្ដីពីការអភិវឌ្ឍធនធានមនុស្ស
C.182 អនុសញ្ញាស្ដីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
R.146 អនុសាសន៍អំពីអាយុអប្បបរមា
C.029 អនុសញ្ញាស្ដីពីការងារដោយបង្ខំ
C.105 អនុសញ្ញាស្ដីពីការលុបបំបាត់ការងារដោយបង្ខំ
C.026 អនុសញ្ញាស្ដីពីយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា
C.131 អនុសញ្ញាស្ដីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា
C.001 អនុសញ្ញាស្ដីពីចំនួនម៉ោងធ្វើការ (វិជ្ជាជីវៈ)
C.014 អនុសញ្ញាស្ដីពីការឈប់សម្រាកប្រចាំសប្ដាហ៍ (វិជ្ជាជីវៈ)
R.116 អនុសាសន៍ស្ដីពីការកាត់បន្ថយចំនួនម៉ោងធ្វើការ
C.155 អនុសញ្ញាស្ដីពីសុវត្ថិភាពការងារ និងសុខភាព
R.164 អនុសាសន៍ស្ដីពីសុវត្ថិភាពការងារ និងសុខភាព

ក៏ដូចជាសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ គោលការណ៍ណែនាំរបស់អង្គការដើម្បីការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) សម្រាប់សហគ្រាសពហុសាសន៍ សេចក្ដីប្រកាសត្រីភាគីនៃអង្គការពលកម្មអន្តរជាតិ (ILO) ស្ដីពីគោលការណ៍ដែលពាក់ព័ន្ធនឹងសហគ្រាសពហុសាសន៍ និងគោលនយោបាយសង្គម គោលការណ៍ណែនាំអង្គការសហប្រជាជាតិស្ដីពីកិច្ចការជំនួញនិងសិទ្ធិមនុស្ស ការព្រមព្រៀងជាសកលរបស់អង្គការសហប្រជាជាតិ និងគោលដៅអភិវឌ្ឍដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិ ចំពោះបណ្ដាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ទាំងអស់។

7.ភាគី ព្រមព្រៀងទៅវិញទៅមក ដូចមានចែងនៅក្នុងក្រមសីលធម៌ស្ដីពីសង្គមនិងបរិស្ថាន (SCoC) របស់ក្រុមហ៊ុន Tchibo ដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ 1 នៃកិច្ចព្រមព្រៀងនេះថាអនុសញ្ញា និងបទដ្ឋានដែលមានចែងក្នុងផ្នែក 6 ព្រមទាំងយុត្តិសាស្ត្រពាក់ព័ន្ធនានារបស់អង្គការពលកម្មអន្តរជាតិ ត្រូវអនុវត្តជំនួសច្បាប់ជាតិ ក្នុងករណីដែលច្បាប់ទាំងនេះផ្ដល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតតិចតួចជាង។

## ការប្ដេជ្ញាចិត្ត

8. ក្រុមហ៊ុន Tchibo ទទួលស្គាល់ថាតួនាទីសហជីព គឺរៀបចំចងក្រងកម្មករនិយោជិតនិងចរចាអនុសញ្ញារួម តំណាងឱ្យកម្មករ និងទទួលស្គាល់សហជីព IndustriALL Global Union និងសហជីពជាដៃគូថាជាដៃគូស្របច្បាប់របស់ខ្លួនសម្រាប់ការសហការទាក់ទងនឹងសិទ្ធិមនុស្ស និងសិទ្ធិសហជីព (ដូចរៀបរាប់លម្អិតនៅផ្នែក 6) ។
9. សហជីព IndustriALL Global Union បញ្ជាក់ថានឹងសហការជាមួយក្រុមហ៊ុន Tchibo ហើយប្ដេជ្ញាធ្វើការងារជាមួយសហជីពទាំងអស់ ក្នុងបណ្ដាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo។

## វិសាលភាព

10. កិច្ចព្រមព្រៀងនេះ ត្រូវគ្របដណ្ដប់បណ្ដាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ជាមួយនឹងអ្នកលក់ អ្នកផ្គត់ផ្គង់ អ្នកផលិត និងអ្នកម៉ៅការបន្តរបស់ខ្លួនទាំងអស់ ហើយត្រូវអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដោយមិនគិតថាតើបានជួលឱ្យបម្រើការងារដោយផ្ទាល់ ឬដោយប្រយោលដោយដៃគូអាជីវកម្មរបស់ក្រុមហ៊ុន Tchibo និងដោយមិនគិតពីមូលដ្ឋានកិច្ចសន្យាការងារ មិនថាក្នុងវិស័យផ្លូវការឬមិនផ្លូវការឡើយ។
11. ចំពោះកន្លែងធ្វើការនៅក្នុងបណ្ដាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ដែលតំណាងដោយសហជីពដែលមិនមែនជាដៃគូជាមួយនឹងសហជីព IndustriALL Global Union នោះ IndustriALL Global Union និង Tchibo ត្រូវទទួលរ៉ាប់រងជូនដំណឹងសហជីពទាំងនេះអំពីកិច្ចព្រមព្រៀងនេះ។ សហជីពដែលមិនមែនជាដៃគូរបស់សហជីព IndustriALL Global Union អាចចូលរួមក្នុងកិច្ចព្រមព្រៀងនេះ ប្រសិនបើមានការយល់ព្រមទៅវិញទៅមកពីភាគី។

**ការអនុវត្ត**

12. ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ត្រូវទទួលរ៉ាប់រងអភិវឌ្ឍ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្ររួមគ្នា ដើម្បីពង្រឹងសិទ្ធិរៀបចំចងក្រងកម្មករនិយោជិត និងការចរចាអនុសញ្ញារួម នៅទូទាំងបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo។
13. ភាគី ត្រូវកំណត់រួមគ្នានូវអនុយុទ្ធសាស្ត្រសម្រាប់ទីផ្សារទិញសំខាន់បំផុតរបស់ក្រុមហ៊ុន Tchibo ព្រមទាំងបណ្តាប្រទេសដែលបានកំណត់ថាមានសារៈសំខាន់ជាយុទ្ធសាស្ត្រ នៅពេលដែលមានគោលបំណងពង្រឹងសិទ្ធិរៀបចំចងក្រងកម្មករនិយោជិត និងការចរចាអនុសញ្ញារួមនៅក្នុងវិស័យឧស្សាហកម្ម។ ភាគី ត្រូវព្រមព្រៀងគ្នាទៅវិញទៅមកអំពីការកំណត់ប្រទេសដែលត្រូវផ្តល់អាទិភាព។
14. ដោយផ្អែកលើយុទ្ធសាស្ត្រទូទៅនិងយុទ្ធសាស្ត្រតាមប្រទេស ភាគី ត្រូវព្រមព្រៀងគ្នាអនុវត្តសកម្មភាពនានាដូចជា៖
    - វិធានការនានា ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈដែលមានលក្ខណៈចាស់ទុំទាំងនៅកម្រិតរោងចក្រ និងនៅកម្រិតឧស្សាហកម្មទាំងមូល
    - ការបង្កើតទំនុកចិត្ត និងសកម្មភាពពង្រឹងសមត្ថភាពនៅកម្រិតរោងចក្រ ដែលរួមមានម្ចាស់រោងចក្រ អ្នកគ្រប់គ្រងរោងចក្រ កម្មករនិយោជិត អ្នកតំណាងកម្មករនិយោជិត សមាជិកសហជីព និងអ្នកតំណាងសហជីព ជាដើម
    - គំនិតផ្តួចផ្តើមកម្រិតឧស្សាហកម្មទាំងមូល ដូចជា សន្ធិសញ្ញាស្តីពីសុវត្ថិភាពអគ្គីភ័យនិងអគារក្នុងប្រទេសបង់ក្លាដេស និងច្បាប់ស្តីពីប្រាក់ឈ្នួលសម្រាប់ការរស់នៅ
    - កិច្ចសហការជាមួយក្រុមហ៊ុននានាក្នុងវិស័យពាក់ព័ន្ធ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌសកលជាមួយសហជីព IndustriALL Global Union ផងដែរ
    - រួមគ្នាជាមួយរដ្ឋាភិបាល ដើម្បីចូលរួមដំណើរការត្រីភាគី ជាមួយបុគ្គលផ្សេងទៀតដែលកាន់ការងារនេះពីអាជីវកម្ម និងអ្នកពាក់ព័ន្ធផ្សេងៗ ដែលត្រូវបានកំណត់និងអញ្ជើញតាមការព្រមព្រៀងទៅវិញទៅមករបស់ភាគី
    - ការមិនមានប្រាស្រ័យទាក់ទងពីក្រុមហ៊ុន Tchibo ដែលមានគោលបំណងជះឥទ្ធិពលលើការសម្រេចចិត្តរបស់កម្មករនិយោជិត នៅក្នុងបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ដែលទាក់ទងទៅនឹងតំណាងសហជីព ការហាមឃាត់រាល់ទម្រង់នៃការរើសអើងដោយផ្អែកលើសកម្មភាពសហជីព និងហាមឃាត់ការរើសអើងប្រឆាំងនឹងកម្មករនិយោជិត ឬតំណាងរបស់ពួកគេដែលទាមទារសិទ្ធិដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។
15. សហជីព IndustriALL Global Union ត្រូវពិនិត្យមើលនូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់កម្មវិធីលើកកម្ពស់គុណភាពសង្គមទូទាំងពិភពលោក ហៅកាត់ថាកម្មវិធី WE (Worldwide Enhancement of Social Quality) ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ 2។ តាមរយៈការចូលរួមរបស់ខ្លួន នៅក្នុងគណៈកម្មាធិការប្រឹក្សាយោបល់របស់កម្មវិធី WE នោះ សហជីព IndustriALL Global Union ត្រូវណែនាំក្រុមហ៊ុន Tchibo អំពីការពង្រឹងសិទ្ធិសហជីព នៅក្នុងកម្មវិធី WE។
16. ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union សហការជាមួយគ្នាទៅវិញទៅមកដោយមានទំនុកចិត្តថាពួកគេអាចដោះស្រាយបញ្ហាជាមួយគ្នា ហើយបញ្ហានានាដែលអាចកើតឡើងក្នុងការអនុវត្ត និងការត្រួតពិនិត្យវិធានការនានាដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។ ភាគីទាំងពីរត្រូវទទួលរ៉ាប់រងជូនដំណឹងទៅវិញទៅមកចំពោះការរំលោភបំពានណាមួយដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះឲ្យបានឆាប់រហ័ស នៅពេលការរំលោភបំពានត្រូវបានរកឃើញ ដើម្បីអនុញ្ញាតឱ្យភាគីអាចអនុវត្តផែនការសកម្មភាពដោះស្រាយកែតម្រូវ ដោយគ្មានការពន្យារពេលហួសកំណត់។
17. ក្នុងករណីសហជីពក្នុងស្រុកដែលជាដៃគូរបស់សហជីព IndustriALL Global Union រកឃើញថាអាចមានការរំលោភបំពានលើការអនុវត្តកិច្ចព្រមព្រៀងនេះនៅក្នុងបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo និងការព្យាយាមរបស់ខ្លួនដើម្បីដោះស្រាយវិវាទនេះ បានបរាជ័យនោះ សហជីព ត្រូវជូនដំណឹងដល់បុគ្គលិកទំនាក់ទំនងរបស់ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ដែលបានចាត់តាំងសម្រាប់ការងារនេះ។
18. ដោយមានការពិគ្រោះយោបល់ជាមួយសហជីព IndustriALL Global Union ក្រុមហ៊ុន Tchibo ត្រូវវាយតម្លៃនិងស៊ើបអង្កេតការរំលោភបំពានដែលអាចមាន និងត្រូវដោះស្រាយដោយផ្ទាល់ជាមួយអ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo តាមតម្រូវការចាំបាច់។
19. ក្នុងករណីមានការបញ្ជាក់ពិតប្រាកដអំពីការរំលោភបំពានលើការអនុវត្តកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ត្រូវអភិវឌ្ឍនិងអនុវត្តរួមគ្នានូវផែនការដោះស្រាយកែតម្រូវ។

20. ក្នុងករណីភាគីមិនអាចសម្រេចបានការដោះស្រាយរួមមួយដែលសមស្រប ដើម្បីដោះស្រាយការរំលោភបំពានដោយពេញចិត្ត ដល់ភាគីទាំងសងខាងទេ ភាគីត្រូវយល់ព្រមស្វែងរកជំនួយការដោះស្រាយកែតម្រូវ និងការដោះស្រាយជម្លោះពីអង្គការ ILO។ ភាគី ត្រូវយល់ព្រមគោរពតាមអនុសាសន៍ចុងក្រោយរបស់អង្គការ ILO ។

**រចនាសម្ព័ន និងការរៀបចំ**

21. ភាគី ត្រូវយល់ព្រមរៀបចំកិច្ចប្រជុំ/សិក្ខាសាលា ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រ និងអនុយុទ្ធសាស្ត្ររបស់ប្រទេស និង ពិនិត្យការអនុវត្តកម្មវិធី WE ក្នុងរយៈពេលបីខែបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ សម្រាប់កិច្ចប្រជុំទាំងនេះ សហជីពដៃគូរបស់សហជីព IndustriALL Global Union អាចនឹងត្រូវបានគេអញ្ជើញឱ្យចូលរួមនៅពេលមានការព្រមព្រៀង ទាំងសងខាងពីភាគីនៃកិច្ចព្រមព្រៀង។

22. បន្ទាប់ពីការអភិវឌ្ឍយុទ្ធសាស្ត្រដំបូង ភាគី ត្រូវយល់ព្រមទៅនឹងការពិនិត្យឡើងវិញចំពោះការអនុវត្តកិច្ចព្រមព្រៀងជារៀងរាល់ ពីរដងក្នុងមួយឆ្នាំ ហើយត្រូវបង្កើតគណៈកម្មការមួយ (តាមន័យនេះហៅថាគណៈកម្មការកិច្ចព្រមព្រៀងក្របខណ្ឌសកល "GFA Committee") ដែលរួមមានអ្នកតំណាងយ៉ាងតិចពីររូបដែលមកពីក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ។

23. ការពិនិត្យឡើងវិញជារៀងរាល់ពីរដងក្នុងមួយឆ្នាំ ត្រូវរួមបញ្ចូល ឬធ្វើឲ្យស្របពេលជាមួយកិច្ចប្រជុំគណៈកម្មការ ប្រឹក្សាយោបល់កម្មវិធី WE។

24. ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ត្រូវចាត់តាំងបុគ្គលទំនាក់ទំនងម្នាក់ (តាមន័យនេះហៅថា "បុគ្គលទំនាក់ទំនង") ដើម្បីដោះស្រាយ និងពិនិត្យតាមដានបញ្ហានានាដែលកើតឡើងនៅកិច្ចប្រជុំជារៀងរាល់ពីរដង ក្នុងមួយឆ្នាំ។ ប្រសិនបើចាំបាច់ ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ត្រូវចាត់តាំង បុគ្គលទំនាក់ទំនងប្រចាំតំបន់បន្ថែមទៀត ដើម្បីជួយគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

25. ចំពោះការអនុវត្តអនុយុទ្ធសាស្ត្ររបស់ប្រទេស ភាគីអាចនឹងយល់ព្រមតែងតាំងក្រុមការងារ (តាមន័យនេះហៅថា "ក្រុមការងារ ប្រចាំប្រទេស") ដែលមានអ្នកតំណាងទាំងពីរគឺក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union។ ដោយ ស្របតាមយុទ្ធសាស្ត្រទូទៅ និងអនុយុទ្ធសាស្ត្ររបស់ប្រទេសពាក់ព័ន្ធនោះ ក្រុមការងារប្រចាំប្រទេសអាចអនុវត្តសកម្មភាព ដូចខាងក្រោម៖
    - វិធានការនានា ដើម្បីបង្កើតបរិយាកាសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈដែលមានភាពចាស់ទុំ ទាំងនៅកម្រិតរោងចក្រ និងនៅកម្រិតឧស្សាហកម្មទាំងមូល។
    - ការបង្កើតទំនុកចិត្ត និងសកម្មភាពពង្រឹងសមត្ថភាពនៅកម្រិតរោងចក្រ ដែលរួមមានម្ចាស់រោងចក្រ អ្នកគ្រប់គ្រង រោងចក្រ កម្មករនិយោជិត តំណាងកម្មករ សមាជិកសហជីព និងតំណាងសហជីព
    - បើមានការចាំបាច់នោះ ជំនួយដំណោះស្រាយការរំលោភបំពានណាមួយលើកិច្ចព្រមព្រៀងនេះចំពោះអ្នកផលិត និង អ្នកផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ដូចមានកំណត់ក្នុងកថាខណ្ឌ 16-19។
    - ប្រសិនបើមានប្រយោជន៍ កិច្ចសហការជាមួយក្រុមហ៊ុននានានៅក្នុងវិស័យដែលពាក់ព័ន្ធដែលបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងក្របខ័ណ្ឌសកលជាមួយសហជីព IndustriALL Global Union ផងដែរ។

    ក្រុមការងារប្រចាំប្រទេស ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាទៀងទាត់ជូនទៅគណៈកម្មការកិច្ចព្រមព្រៀងក្របខណ្ឌ សកល (កថាខណ្ឌ 22) និងបុគ្គលទំនាក់ទំនងដែលបានចាត់តាំង (កថាខណ្ឌ 24) ។

26. ក្រុមការងារប្រចាំប្រទេសអាចជួបគ្នាជាទៀងទាត់ដូចបានព្រមព្រៀងគ្នាទៅវិញទៅមកដោយសមាជិកក្នុងក្រុមការងារប្រចាំ ប្រទេស ដែលមកពីសហជីព IndustriALL Global Union និងក្រុមហ៊ុន Tchibo ។

27. ភាគី ត្រូវយល់ព្រមធ្វើការដោយតម្លាភាព សហការ និងដោយស្មោះត្រង់ ដើម្បីធានាបំពេញគោលបំណងទាំងសងខាងនៅក្នុង កិច្ចព្រមព្រៀងនេះ។

28. ក្រុមហ៊ុន Tchibo ត្រូវចេញថ្លៃចំណាយលើការអនុវត្តកម្មវិធី និងកិច្ចប្រជុំដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ។

**ព័ត៌មាន និងសិទ្ធិក្នុងការទទួលបានព័ត៌មាន**

29. ក្រុមហ៊ុន Tchibo ត្រូវផ្តល់ជូនព័ត៌មានចាំបាច់នៅតាមបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ខ្លួនជូនអង្គភាព គ្រប់គ្រងសហជីព IndustriALL Global Union ។ សហជីព IndustriALL Global Union ត្រូវទទួលរ៉ាប់រងរក្សាការសម្ងាត់ យ៉ាងតឹងរ៉ឹងចំពោះព័ត៌មានអំពីបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហារ ហើយត្រូវទទួលខុសត្រូវចំពោះការប្រើប្រាស់ សមស្របដោយសហជីព និងសហជីពដៃគូរបស់ខ្លួន។

30. ក្រុមហ៊ុន Tchibo ត្រូវទទួលរ៉ាប់រងជូនដំណឹងដល់អ្នកផ្គត់ផ្គង់ផលិតផលខាងក្រៅរបស់ខ្លួនអំពីមាតិកា និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ រីឯសហជីព IndustriALL Global Union ត្រូវជូនដំណឹងដូចគ្នាដល់សហជីពដៃគូរបស់ខ្លួន និងសហជីពពាក់ព័ន្ធផ្សេងទៀត តាមការគួរ។

31. អង្គភាពគ្រប់គ្រងសហជីព IndustriALL Global Union ត្រូវសម្របសម្រួលថារចនាសម្ព័ន្ធសហជីពនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ មានការយល់ដឹងអំពីសកម្មភាពដែលក្រុមហ៊ុន Tchibo អភិវឌ្ឍ ទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនៅក្នុងប្រទេសរបស់ខ្លួន។

32. ក្រុមហ៊ុន Tchibo ត្រូវធានាការបកប្រែភាសានៃកិច្ចព្រមព្រៀងនេះ ជាភាសាដែលពាក់ព័ន្ធទាំងអស់ ដែលបានព្រមព្រៀងទាំងសងខាងជាមួយសហជីព IndustriALL Global Union ។

33. ក្រុមហ៊ុន Tchibo ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យសហជីព IndustriALL Global Union និងសហជីពដៃគូនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ អាចជួបផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ផលិតផល និងរោងចក្រនានានៅតាមបណ្តាញផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo ដោយពិចារណាអំពីស្ថានភាពប្រវត្តិសាស្ត្រ នយោបាយ និងសង្គមនៅតំបន់នីមួយៗ។ ការអនុញ្ញាតនេះ ត្រូវបានផ្តល់ជូនដោយផ្អែកលើយន្តការនានា ដែលថ្នាក់គ្រប់គ្រងទាំងសហជីព IndustriALL Global Union និងក្រុមហ៊ុន Tchibo ចាត់ទុកថាជាការចាំបាច់។ សហជីព IndustriALL Global Union ទទួលស្គាល់និងព្រមព្រៀងថា សហជីពណាមួយក៏ដោយអាចចូលក្នុងបរិវេណអ្នកផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo បានលុះត្រាតែទទួលបានការយល់ព្រមជាមុនសិនពីដៃគូអាជីវកម្មនោះសិន។ ដូច្នេះភាគីទាំងពីរព្រមព្រៀងថានៅក្នុងករណីដែលសហជីព IndustriALL Global Union ឬសហជីពដៃគូខ្លួនត្រូវការជួបជាមួយកម្មករនិយោជិតនៅក្នុងទីបរិវេណរបស់អ្នកផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo សហជីព IndustriALL Global Union ឬសហជីពដៃគូរបស់ខ្លួន ត្រូវស្នើសុំក្រុមហ៊ុន Tchibo ដើម្បីទទួលបានការយល់ព្រមជាចាំបាច់ពីដៃគូអាជីវកម្ម។

34. ក្រុមហ៊ុន Tchibo និងសហជីព IndustriALL Global Union ត្រូវប្រព្រឹត្តតាមការអនុវត្តវិធានការសមស្រប ដើម្បីបង្កើននិងពង្រឹងចំណេះដឹងនិងជំនាញរបស់រោងចក្រផ្គត់ផ្គង់ផលិតផលមិនមែនម្ហូបអាហាររបស់ក្រុមហ៊ុន Tchibo និងសហជីពដៃគូ IndustriALL Global Union ក្នុងការជួយគាំទ្រដល់កិច្ចព្រមព្រៀងនេះ។

## ថេរវេលា និងការបញ្ចប់

35. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានដោយគិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខានេះនិងត្រូវស្ថិតនៅជាធរមានក្នុងថេរវេលាមិនកំណត់ ប្រសិនបើមិនបានបញ្ចប់ដោយភាគីណាមួយតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សររយៈពេលប្រាំមួយខែមុន។

## ប្រធានសក្តិ

36. ការពន្យារពេល ឬការខកខានណាមួយ ដោយភាគីក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងនេះ មិនត្រូវចាត់ទុកជាការមិនបំពេញកាតព្វកិច្ចតាមកិច្ចព្រមព្រៀងទេ ប្រសិនបើ និងក្នុងវិសាលភាពនិងរយៈពេល ដែល (i) ការពន្យាពេលឬការខកខាននេះត្រូវបានបង្កឡើងដោយព្រឹត្តិការណ៍ឬការកើតឡើងហួសពីការគ្រប់គ្រង និងដោយគ្មានកំហុស ឬការធ្វេសប្រហែសពីភាគីដែលត្រូវបំពេញកាតព្វកិច្ច ឬភាគីផ្សេងទៀតដែលបំពេញការងារក្រោមបង្គាប់ ឬតាមរយៈភាគីដែលត្រូវបំពេញកាតព្វកិច្ច ហើយ (ii) ភាគីដែលពន្យាពេលឬខកខានបំពេញកាតព្វកិច្ច មិនអាចរារាំងការពន្យាពេលឬការខកខាននេះបានបើទោះជាបានអនុវត្តដោយយកចិត្តទុកដាក់សមហេតុផល។ ព្រឹត្តិការណ៍ដែលត្រូវបានចាត់ទុកថា ហួសពីការគ្រប់គ្រងរបស់ភាគីនៃកិច្ចព្រមព្រៀងនេះមានដូចជា៖ ករណីប្រធានសក្តិ ការដកសិទ្ធិឬការរឹបអូសយកអគារដោយអាជ្ញាធររដ្ឋាភិបាលឬយោធា សង្គ្រាម ការបះបោរ និងការបំផ្លិចបំផ្លាញដោយចេតនាឬកុប្បកម្ម ទឹកជំនន់ អាកាសធាតុធ្ងន់ធ្ងរមិនធម្មតាដែលមិនអាចត្រូវបានគេរំពឹងទុកដោយសមហេតុផលឬគ្រោះធម្មជាតិផ្សេងទៀត ឬការកើតឡើងស្រដៀងគ្នាផ្សេងទៀត។

## បទប្បញ្ញត្តិទូទៅ

37. លុះត្រាតែមានចែងយ៉ាងច្បាស់លាស់ក្នុងកិច្ចព្រមព្រៀងនេះ ការផ្លាស់ប្តូរ ការកែសម្រួល ឬការកែតម្រូវកិច្ចព្រមព្រៀងនេះ មិនអាចធ្វើបាននោះទេ លុះត្រាតែមានការសរសេរជាលាយលក្ខណ៍អក្សរ និងបានចុះហត្ថលេខាដោយភាគី។

38. ប្រសិនបើបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់ថាគ្មានសុពលភាព ឬមិនអាចអនុវត្តបាន នៅផ្នែកណាមួយឬទាំងមូល អសុពលភាពឬការអនុវត្តមិនបាននេះ ប៉ះពាល់ដល់តែត្រឹមបទប្បញ្ញត្តិឬផ្នែកនៃបទប្បញ្ញត្តិនោះតែប៉ុណ្ណោះ ហើយផ្នែកផ្សេងទៀតនៃបទប្បញ្ញត្តិនេះ និងបទប្បញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះត្រូវបន្តអនុវត្ត និង

មានប្រសិទ្ធភាពពេញលេញ។

កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានិងអនុវត្តដោយភាគីទាំងពីរ ចាប់ពីថ្ងៃនិងឆ្នាំ ដូចកំណត់ខាងក្រោម។

សម្រាប់ Tchibo GmbH

Hamburg, 27 កញ្ញា 2016

____________________________

Dr. Markus Conrad
អគ្គនាយកក្រុមហ៊ុន

____________________________

Thomas Linemayr
សមាជិកគណៈកម្មការគ្រប់គ្រង

____________________________

Senay Kücük Tansu
សមាជិកគណៈកម្មការគ្រប់គ្រង ផ្នែកផលិតផលមិនមែនអាហារ

សម្រាប់ IndustriALL Global Union

Hamburg, 27 កញ្ញា 2016

____________________________

Jyrki Raina
អគ្គលេខាធិការ